# សុន្ទរកថា

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រីយឹមឆៃលី
## ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

## ក្នុងអង្គសិក្ខាសាលាស្តីពី
## "ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន"

ខេត្តសៀមរាបថ្ងៃទី២៩-៣១ ខែឧសភា ឆ្នាំ២០១៣

***ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន***

ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ថ្ងៃនេះខ្ញុំមានកិត្តិយស និងសោមនស្សរីករាយ ដោយបានចូលរួមក្នុងកម្មវិធីបើកអង្គសិក្ខាសាលាស្តីពី "**ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន**" ដែលរៀបចំដោយអង្គការពលកម្មអន្តរជាតិ សហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។ នេះមិនមែនជាប្រការចៃដន្យទេ ដែលអង្គសិក្ខាសាលានេះ ត្រូវបានរៀបចំនៅលើទឹកដីខេត្តសៀមរាបនៃព្រះរាជាចក្រកម្ពុជា ដើម្បីអោយសិក្ខាកាមទាំងអស់អាចទស្សនា និងស្វែងយល់ពីប្រវត្តិសាស្ត្រដ៏អស្ចារ្យរបស់ប្រទេសកម្ពុជា។

ខេត្តសៀមរាបនេះ នឹងបង្ហាញឱ្យឃើញពីសម្បត្តិវប្បធម៌ដ៏សម្បើមនិងអស្ចារ្យរបស់កម្ពុជា ជាព្រះរាជាណាចក្រអច្ឆរិយៈ ជាទឹកដីដែលប្រទេសជាតិនិងអរិយធម៌ត្រូវបានកសាងឡើងដោយមានការចូលរួមពីសំណាក់ប្រជាជនហើយដែលបានឈានដល់ចំណុចកំពូលនៅសតវត្សទី១៣ ហើយខេត្តសៀមរាបនេះ ក៏នឹង

បង្ហាញពីស្លាកស្នាមនៃសង្គ្រាម ដែលប្រទេសជាតិនិងអរិយធម៌ត្រូវបានបំផ្លិចបំផ្លាញស្ទើរដល់ឫសគល់ ដែលទឹកដីសម្បត្តិវប្បធម៌នេះ បានប្រែក្លាយទៅជាវាលពិឃាត កាលពីជាង៣ទសវត្សមុននេះ។ ប៉ុន្តែប្រការដែលសំខាន់បំផុតនោះ ឯកឧត្តម លោក លោកស្រីអាចមើលឃើញ បន្ទាប់ពីរបបប្រល័យពូជសាសន៍ក្នុងទសវត្សឆ្នាំ១៩៧០ ដែលប្រជាជនកម្ពុជា បានក្រោកឈរឡើងវិញដោយខ្លួនឯង ដោយឆ្លងកាត់ដំណាក់កាលនៃការសង្គ្រោះជាតិ ការកសាងជាតិ ការផ្សះផ្សារជាតិ ការស្តារនីតិសម្បទានិងការអភិវឌ្ឍជាតិ ពីដំណាក់កាលឆ្នាំសូន្យ រហូតមានអ្វីៗមកដល់បច្ចុប្បន្ននេះ ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់វគ្គដំបូងនៃអង្គសិក្ខាសាលានេះ ខ្ញុំសូមចែករំលែកនូវទស្សនៈខ្លួនខ្ញុំផ្ទាល់លើការអភិវឌ្ឍន៍ការគាំពារសង្គមនៅកម្ពុជា។ នៅគ្រប់ដំណាក់កាលនៃការអភិវឌ្ឍជាតិ ការគាំពារសង្គម គឺជាឧបករណ៍ដ៏ចាំបាច់មួយសម្រាប់កម្ពុជា។ វប្បធម៌នៃការចែករំលែកការជួយគ្នាទៅវិញទៅមកនិងទំនាក់ទំនងសម្ព័ន្ធគ្រួសារសុទ្ធសឹងតែជាផ្នែកមួយនៃប្រពៃណីខ្មែរ។ ប្រជាជនកម្ពុជា បានធ្វើដំណើរលើផ្លូវមួយយ៉ាងវែងក្នុងប្រវត្តិសាស្ត្រក្នុងការតស៊ូការពារជីវិតរស់នៅ ការការពារអធិបតេយ្យភាព ឯកភាពជាតិ ឯករាជ្យ បូរណភាពទឹកដីនិងមោទនភាពជាតិ។ តាំងពីឆ្នាំ ១៩៧៩មក ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់ ជម្នះគ្រប់ឧបសគ្គ ដោយទាញយកឱកាសគ្រប់ការប្រឈម ដើម្បីដំណើរការកសាងជាតិល្អប្រសើរ និងប្រែក្លាយព្រះរាជាណាចក្រកម្ពុជា មកជាប្រទេសមួយប្រកបដោយសេចក្តីសង្ឃឹម និងកិត្តិយសនៅអាស៊ីអាគ្នេយ៍។ រាជរដ្ឋាភិបាល មានចក្ខុវិស័យច្បាស់លាស់ សម្លឹងមើលទៅអនាគតវែងឆ្ងាយក្នុងការអនុវត្តកំណែទម្រង់នានាដែលបានដាក់ចេញ ដោយបានសម្របខ្លួនទៅគ្រប់ស្ថានភាពដែលអាចកើតឡើងជាយថាហេតុ និងធ្វើការកែលម្អជាបន្តបន្ទាប់ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យបានសម្រេចដល់គោលដៅដែលបានគ្រោងទុក ហើយការគាំពារសង្គម គឺជាស្នូលកណ្តាលនៃចក្ខុវិស័យនេះ។

ការគាំពារសង្គម គឺជាអាទិភាពមួយដ៏សំខាន់នៃរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ត្រូវបានរៀបចំនិងអនុម័តដោយរាជរដ្ឋាភិ–បាលកម្ពុជានៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ តាមរយៈការសម្របសម្រួលដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។ ប្រការនេះ បានកើតឡើងនៅពេលដែលមានការផ្ទុះឡើងនៃកលិយុគសេដ្ឋកិច្ចសកល ស្បៀងអាហារនិងហិរញ្ញវត្ថុ នាឆ្នាំ២០០៨–២០០៩ ដែលបណ្តាលឱ្យកើតមានផលប៉ះពាល់ដល់ប្រជាជនជាច្រើននៅលើពិភពលោក តាមរយៈការកើនឡើងហានិភ័យសង្គម និងសេដ្ឋកិច្ច ពិសេសចំពោះប្រជាជនដែលរស់នៅក្រោម ឬនៅក្បែរបន្ទាត់នៃភាពក្រីក្រ។ គ្រោះធម្មជាតិនិងឧប្បត្តិហេតុនៃមហន្តរាយ

បណ្តាលមកពីអាកាសធាតុ បានដាក់បន្ថែមសម្ពាធទៅលើប្រជាជន ដោយជះឥទ្ធិពលលើជីវិតទ្រព្យសម្បត្តិធនធានក្នុងសហគមន៍ និងសេដ្ឋកិច្ចក្នុងតំបន់។ ផលប៉ះពាល់ ដែលកើតឡើងក្នុងពេលព្រមគ្នានៃហានិភ័យ និងវិបត្តិទាំងនេះ បានជំរុញឱ្យមានការគិតពិចារណាទៅលើតួនាទីនៃការគាំពារសង្គម។ រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិចដ៏ទៃទៀត មិនត្រឹមតែបានដោះស្រាយបញ្ហានេះដោយអន្តរាគមន៍ផ្ទាល់ចំពោះស្ថានការណ៍ចំពោះមុខប៉ុណ្ណោះទេ តែថែមទាំងបានធ្វើដំណើរឆ្ពោះទៅកាន់ដំណោះស្រាយជាលក្ខណៈទូលំទូលាយ ស៊ីជម្រៅចម្រុះនិងជាប្រព័ន្ធ ដែលមានលទ្ធភាពក្នុងការពង្រឹងសមត្ថភាព បន្សាំនិងការងើបឡើងវិញពីកលិយុគ ដូចដែលបានកំណត់ឡើងក្នុងទស្សនៈវិស័យនៃការអភិវឌ្ឍដោយមានការចូលរួម គឺជាការរៀបចំបង្កើតឡើងនូវ "យុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា "។

## ***ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន***

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងនេះក៏ដោយ ក៏ការពង្រីកវិសាលភាពនៃការគាំពារសង្គម គឺជាបញ្ហាប្រឈមមួយសម្រាប់សង្គមកម្ពុជា។ ការគាំពារសង្គមនៅពេលបច្ចុប្បន្ននេះ ផ្តោតគោលដៅទៅលើក្រុមប្រជាជនជាក់លាក់ (ដូចជានិយោជិកក្នុងវិស័យឯកជន តាមរយៈបេឡាសន្តិសុខសង្គម) ឬ ហានិភ័យជាក់លាក់ (ដូចជាហានិភ័យសុខភាព តាមរយៈមូលនិធិសមធម៌សុខាភិបាល ដែលគ្របដណ្តប់លើជនក្រីក្រប្រមាណ៦០%)។ សមាហរណកម្មអាស៊ាននៅឆ្នាំ២០១៥ខាងមុខនេះ នឹងជះឥទ្ធិពលមួយចំនួនដល់សេដ្ឋកិច្ច និងសង្គមកម្ពុជា។

សមាហរណកម្មអាស៊ាន អាចជាបន្ទុកមួយដល់ជនក្រីក្រ និងជនងាយរងគ្រោះក្នុងប្រទេសមួយចំនួន ប្រសិនបើប្រព័ន្ធគាំពារសង្គមដ៏ស៊ីជម្រៅមួយ នៅពុំទាន់រៀបចំឡើងសមស្រម ដោយផ្តោតគោលដៅលើការគាំពារជនងាយរងគ្រោះបំផុត និងលើកកម្ពស់សក្តានុពលពេញលេញរបស់យុវជន និងមនុស្សពេញវ័យការងារ ។ ក្នុងមូលដ្ឋាននេះហើយ ដែលយុទ្ធសាស្ត្រជាតិគាំពារសង្គមរបស់ប្រទេសកម្ពុជា បានផ្តល់នូវទស្សនៈវិស័យក្នុងការបង្កើតប្រព័ន្ធគាំពារសង្គមស៊ីជម្រៅមួយក្នុងលក្ខណៈជាដំណាក់កាល គឺដោយចាប់ផ្តើមពីការបង្កើតការគាំពារសង្គមជាមូលដ្ឋានសម្រាប់ប្រជាជនគ្រប់រូបដែលត្រូវការ និងធានាថា ប្រជាជនកាន់តែច្រើនទៅៗ នឹងទទួលបានមនុញ្ញផលពីការគាំពារសង្គម។ ប្រការនេះ គឺស្របគ្នានឹងទស្សនវិស័យរបស់អង្គការពលកម្មអន្តរជាតិ និងការសម្រេចចិត្តជាលក្ខណៈអន្តរជាតិថ្មីៗ ពាក់ព័ន្ធនឹងការគាំពារសង្គមមូលដ្ឋាន នៅឆ្នាំ២០១២។ យុទ្ធសាស្ត្រជាតិគាំពារសង្គម (យ.ជ.គ.ស) ដាក់ចេញនូវក្របខណ្ឌសម្រាប់ការគាំពារសង្គមដែល

មានលក្ខណៈស៊ីជម្រៅ និងនិរន្តរភាពសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបក្នុងដំណាក់កាលវែង។ ប្រការនេះរាប់បញ្ចូលទាំងគម្រោងដោយមាននិងដោយពុំមានវិភាគទាន។ ការបង្កើតឡើងនូវការគាំពារសង្គម ដែលមានលក្ខណៈទូលំទូលាយនិងស៊ីជម្រៅ គឺមានន័យថាជាការធានាឱ្យមានការពាក់ព័ន្ធគ្នារវាង សមាសភាគនានា (ដោយមាននិងពុំមានវិភាគទាន) ហើយត្រូវបានរៀបចំឡើងស្របគ្នាឆ្ពោះទៅកាន់ប្រព័ន្ធមួយ ដែលមាននិរន្តរភាព ក្នុងនោះគឺ :

- សម្រាប់អ្នកដែលអាចមានលទ្ធភាពបង់ថ្លៃដល់កម្មវិធីគាំពារសង្គម អាចទទួលយកដោយពឹងផ្អែកទៅលើភាគទានជាផ្លូវការរបស់ពួកគាត់
- ហើយសម្រាប់អ្នកដែលពុំអាចមានលទ្ធភាព គាត់នឹងពឹងផ្អែកទៅលើរដ្ឋក្នុងការឧបត្ថម្ភរហូតដល់ពេល ដែលពួកគាត់អាចបង្កើតសមត្ថភាពក្នុងអំឡុងពេលមួយ
- សមាសភាគទាំងពីរនេះមានទំនាក់ទំនងនិងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក នៅក្នុងប្រព័ន្ធដ៏ស៊ីជម្រៅនៃការគាំពារសង្គមជាមូលដ្ឋាន។

គួរបញ្ជាក់ផងដែរថាយុទ្ធសាស្ត្រជាតិគាំពារសង្គម គឺជាលទ្ធផលនៃការពិភាក្សាអស់រយៈពេលជាង ២ឆ្នាំ ដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានដើរតួនាទីសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និយោជិកនិងនិយោជកវិស័យឯកជន សង្គមស៊ីវិលនិងដៃគូអភិវឌ្ឍ។ ខ្ញុំសូមឆ្លៀតឱកាសនេះ សម្តែងនូវសេចក្តីថ្លែងអំណរគុណចំពោះអង្គការពលកម្មអន្តរជាតិ ដែលបានសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្នុងរយៈកាលកន្លងមក ហើយខ្ញុំសូមឱ្យកិច្ចសហប្រតិបត្តិការនេះ នឹងបន្តទៅក្នុងដំណាក់កាលនៃការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមជាបន្តទៀត។

*ឯកឧត្តមលោកជំទាវភ្ញៀវជាតិនិងអន្តរជាតិជាទីរាប់អាន*

ការសម្របសម្រួល គឺជាសសរស្តម្ភយ៉ាងសំខាន់នៃការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ដែលបានចែងថា *"ប្រការសំខាន់នៃការសម្របសម្រួល គឺការបង្កើតរចនាសម្ព័ន្ធ និងយន្តការសមស្របមួយដើម្បីសម្របសម្រួលដល់ការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ដែលធានាឱ្យមានការត្រួតពិនិត្យគោលនយោបាយ ការពិនិត្យតាមដាននិងវាយតម្លៃការគ្រប់គ្រងចំណេះដឹងនិងព័ត៌មាន និងការកសាងសមត្ថភាព"*។ វិញ្ញាសាចម្បងបំផុតដែលប្រទេសកម្ពុជាកំពុងពិចារណាក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺការជំរុញតួនាទីរដ្ឋបាលមូលដ្ឋានក្នុងការអនុវត្តកម្មវិធីគាំពារសង្គមដែលជាកត្តាគន្លឹះក្នុងការធានាថាកម្មវិធី ឬអន្តរាគមន៍គាំពារសង្គម នឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធិភាព និងលើកកម្ពស់សមធម៌នៅថ្នាក់មូលដ្ឋាន។ ទិសដៅនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺដើម្បីបង្កើតនិងលើក

កម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលចាត់ទុកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការបង្កិតសេវាសាធារណៈឱ្យកាន់តែទៅជិតប្រជាពលរដ្ឋ ហើយរំពឹងថានឹងទទួលបាននូវផលប្រយោជន៍ធំៗចំនួនបីដូច ខាងក្រោម ៖

- ទី១ ៖ ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅក្នុងការ ធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន ដែលនេះគឺជាការពង្រឹងនិងពង្រីកនូវការចូលរួមជាសាធារណៈ នៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ ផ្អែកលើលទ្ធផលនៃការចូលរួមនេះ តម្រូវការនិងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតបកាន់តែប្រសើរឡើង។ ដូច្នេះតាមរយៈការអនុវត្តកំណែទម្រង់នេះ នឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានភាពល្អប្រសើរ និងការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិថែមទៀត
- ទី២ ៖ ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាព ព្រោះអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះ ត្រូវបានផ្ទេរ ឬបង្កិតឱ្យទៅជិតប្រជាពលរដ្ឋ
- ទី៣ ៖ ការបង្កើននូវលទ្ធភាពនៃការកៀរគរប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើឆន្ទៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជាការកៀរគរធនធានរបស់វិស័យឯកជននានា ឱ្យចូលរួមជាមួយធនធានរបស់អាជ្ញាធរមូលដ្ឋានក្នុងការវិនិយោគលើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

ដើម្បីជំរុញគោលការណ៍ខាងលើនេះ ឱ្យក្លាយជាសកម្មភាពក្នុងបរិបទនៃការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដោយមានការចូលរួមសម្របសម្រួលនៃរដ្ឋបាលមូលដ្ឋាន ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានផ្តួចផ្តើមរៀបចំ **"យន្តការផ្តល់សេវាសង្គម"** ដែលនឹងអនុវត្តសាកល្បងនៅខេត្តសៀមរាបនេះ។ យន្តការនេះគឺជាគំរូនៃយន្តការច្រកចេញចូលតែមួយសម្រាប់ការគាំពារសង្គម និងសេវាការងារ។ ពិសេសជាងនេះទៅទៀត "យន្តការផ្តល់សេវាសង្គម" នឹងចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តការគាំពារសង្គមនៅកម្ពុជា ដែលពាក់ព័ន្ធនឹង៖ ការផ្តល់សេវាឱ្យចំគោលដៅដល់ជនក្រីក្រ និងជនងាយរងគ្រោះ ការគ្រប់គ្រងព័ត៌មាននិងទិន្នន័យ ការពិនិត្យតាមដាននិងវាយតម្លៃ ការសម្របសម្រួលនិងសុខដុមនីយកម្មរវាងកម្មវិធីដែលមានស្រាប់ និងការកសាងសមត្ថភាពនិងភាពជាអ្នកដឹកនាំរបស់រដ្ឋបាលមូលដ្ឋាន។

កម្មវិធីសិក្ខាសាលាស្តីពី "ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន" ត្រូវបានរៀបចំឡើងក្នុងពេលដែលប្រទេសកម្ពុជា កំពុងបង្ហាញនូវកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំ យន្តការសម្របសម្រួលអន្តរស្ថាប័ន ក៏ដូចជាការសម្របសម្រួល រវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សិក្ខាសាលានេះ ក៏ជាកាលានុវត្តភាពដ៏ពិសេសមួយក្នុងការស្វែងយល់ និងដកស្រង់បទពិសោធន៍រវាងប្រទេសជាច្រើន រួមមានម៉ាឡេស៊ី ឥណ្ឌា ថៃ ប៉ាគីស្ថាន អាហ្វ្រិកខាងត្បូង ឈីលី ប្រេស៊ីល និងប្រទេសជាច្រើន ដែលបានបង្កើត និងអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមស្រដៀងគ្នា និងប្រកបដោយជោគជ័យក្នុងការពង្រីកការគាំពារសង្គមជាមូលដ្ឋាន។

ខ្ញុំសូមប្រសិទ្ធិពរឱ្យការស្នាក់នៅរបស់ឯកឧត្តម លោកជំទាវ លោកលោកស្រី នៅលើទឹកដីអង្គរនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយផាសុកភាព និងភាពសប្បាយរីករាយ។ ខ្ញុំមានកិត្តិយសសូមប្រកាសបើកអង្គសិក្ខាសាលាស្តីពី "ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន" ចាប់ពីពេលនេះតទៅ។

សូមអរគុណ